ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## សាលក្រមព្រហ្មទណ្ឌ

-លេខ ៣៣ "ក១" ក្រ១១
-ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ៣២០៨
ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១
-សំណុំរឿងស៊ើបសួរលេខ ២៤៦២
ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១
-សំណុំរឿងជំនុំជម្រះលេខ ៣៩៥០
ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១
D

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ០០ នាទីរសៀល នៅសាលសវនាការទី៧ ជាន់ទី៥ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣២០៨ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] **ទិចិត្រ** ហៅ **សាល** ភេទប្រុស កើតឆ្នាំ២០០៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅស[redacted] រាជធានីភ្នំពេញ អាសយដ្ឋាននៅផ្ទះជួល ផ្លូវលំលេខ៥ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឡាយ (ស) ម្តាយឈ្មោះ [redacted] សុវណ្ណារី (រ) រៀនថ្នាក់ទី៩ ជានីតិជន ទោសពីមុនគ្មាន។

ដីកាបង្គាប់ឃុំខ្លួនលេខ:៥៧៤១ ង.ដ.ឃ.ជ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១នៅមណ្ឌលអប់រំកែប្រែទី១(ម១)។

ជាប់ចោទពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៧០១ ផ្លូវលេខ១២៨ កែងផ្លូវលេខ២៥៧ ក្រុមទី៣៥ ភូមិ១០ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ [redacted] **សៀវម៉េន** ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ២៨$H^2$ ផ្លូវបេតុង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

-លោកមេធាវី [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] វិចិត្រ អាសយដ្ឋានការិយាល័យនៅអាគារC7(ដឺហ័រធូនថៅវើ)ជាន់ទី១៥ យូនីតH១៥០៣ ផ្លូវលេខ១៨២ កែង១៦១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

-លោក [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] វិចិត្រ អាសយដ្ឋានការិយាល័យនៅអាគារC7(ដឹហ័រធូនថៅវើ)ជាន់ទី១៥ យូនីតH១៥០៣ ផ្លូវលេខ១៨២ កែង១៦១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៦ និង៣០នាទី ជនរងគ្រោះឈ្មោះ [redacted] សៀវម៉េន បានជិះម៉ូតូមួយគ្រឿងម៉ាក HONDA C125 ស៊េរីឆ្នាំ២០០៩ ពណ៌ខ្មៅ ចេញពីកន្លែងធ្វើការនៅមុំផ្លូវលេខ២០០២



Scanned with CamScanner

សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ ក្នុងគោលបំណងទៅជួបមិត្តភក្តិនៅម្តុំក្រោយមន្ទីរពេទ្យកុមារជាតិ ដោយជិះតាមបណ្តោយផ្លូវលេខ១២៨ លុះមកដល់ចំណុចមុខផាកការហ្វេដែលមានទីតាំងផ្ទះលេខ៧០១ ផ្លូវលេខ១២៨ កែងផ្លូវលេខ២៥៧ ក្រុមទី១០ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពេលនោះជនរងគ្រោះបានឈប់ម៉ូតូរួចបានលើកទូរស័ព្ទម៉ាក IPHONE XS ពណ៌ខ្មៅ និយាយទៅកាន់មិត្តភក្តិស្រាប់តែជនជាប់ចោទចំនួន០៣នាក់ មានឈ្មោះ ចំរើន ជិះម៉ូតូមួយគ្រឿងម៉ាកHONDA C125 ស៊េរីឆ្នាំ២០២០ ,ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ បុល ជិះម៉ូតូមួយគ្រឿងម៉ាក់ HONDA C125 ស៊េរីឆ្នាំ២០២១ ពណ៌ខ្មៅ ពុំចាំស្លាកលេខដោយជនជាប់ចោទឈ្មោះ [redacted] វិចិត្រ និងឈ្មោះ បុល ជាអ្នកជិះបិតគូទ ចំណែកជនជាប់ចោទឈ្មោះ ចំរើន ក៏បានធ្វើសកម្មភាពឆក់បានជិះម៉ូតូពីក្រោយខាងស្តាំដៃជនរងគ្រោះរួចជនជាប់ចោទឈ្មោះ ចំរើន បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃរបស់ជនរងគ្រោះបានសម្រេច រួចជនជាប់ចោទទាំង៣បានជិះម៉ូតូបញ្ច្រាស់ផ្លូវគេចខ្លួន ភ្លាមនោះជនរងគ្រោះក៏បានស្រែកថាចោរៗដើម្បីឱ្យគេជួយក៏ត្រូវបានអ្នកដំណើរតាមផ្លូវបានជិះម៉ូតូដេញតាមជនជាប់ចោទឈ្មោះ [redacted] វិចិត្រ រហូតដល់ចំនុចផ្ទះលេខ៤១២ ផ្លូវលេខ២៤៥ ក្រុមទី៣១ ភូមិ១១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ក៏បានដួលម៉ូតូភ្លាមនោះ ជនជាប់ចោទឈ្មោះ បុល ដែលជិះខាងក្រោយក៏បានលើកម៉ូតូ ហើយជិះគេចខ្លួនបាត់ជាមួយឈ្មោះ ចំរើន បាត់តែម្តង។ប្រជាពលរដ្ឋចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] វិចិត្រ យកមកប្រគល់ជូនប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកល្អក់ទី១ ដើម្បីសាកសួរ។

-បានឃើញ របាយការណ៍សំយោគលេខ ១២១ រ.ប.ក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌគោក នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៤៨៣ អ.យ.ទ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៦៧៨ អ.យ.ទ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤៩៦២ ង.ដ.ជ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ បានឆ្លើយនៅថា៖កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១វេលាម៉ោង១៤ និង ០០ នាទីរសៀល ឈ្មោះ បុល បានបបួលខ្លួនទៅផឹកស្រា ហើយខ្លួនក៏បានឱ្យឈ្មោះ បុល មកយកខ្លួននៅផ្ទះ។ពេលជិះតាមផ្លូវខ្លួនជាអ្នកឌុបឈ្មោះ បុល ហើយឈ្មោះ បុល ក៏បានទាក់ទងទៅឈ្មោះ ចំរើន មកជួបគ្នានៅស្តុបណូគា។ បន្ទាប់មកពួកខ្លួនក៏បានជិះម៉ូតូមកដល់ចំណុចសន្ទរមុខដើម្បីរកកន្លែងផឹកស៊ីក៏ស្រាប់តែឈ្មោះ ចំរើនបានស៊ីផ្លេឱ្យខ្លួនបកក្រោយវិញ ហើយឈ្មោះ ចំរើន បានជិះម៉ូតូទៅក្បែរជនរងគ្រោះដែលកំពុងឈរនិយាយទូរស័ព្ទ ហើយឈ្មោះ ចំរើន ក៏បានឆក់ទូរស័ព្ទពីជនរងគ្រោះបានសម្រេច។បន្ទាប់ជនរងគ្រោះក៏បានស្រែកថាចោរៗ។ពេលនោះពួកខ្លួនក៏បានជិះម៉ូតូគេចខ្លួនដោយឈ្មោះ ចំរើន ជិះបត់ទៅខាងឆ្វេងផ្លូវ ហើយជិះបត់ទៅខាងស្តាំផ្លូវ។ហើយបន្ទាប់ទៀតមានមនុស្សប្រុសពីរនាក់ជិះម៉ូតូម៉ាក PCX ដេញខ្លួនដល់ចំណុចបេនឡានវិទ្ធិមុនីផ្សារដើមគរ ហើយខ្លួនក៏ដួលម៉ូតូឈ្មោះ បុល ក៏បានលើកម៉ូតូជិះបាត់តែម្តង។ហើយពេលគេក៏ហៅសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនប្រហែលមួយអាទិត្យ មុនពេលកើតហេតុ។ខ្លួនសារភាពថាពិតជាចូលរួមធ្វើសកម្មភាពឆក់ទូរស័ព្ទរបស់ជនរងគ្រោះមែនដោយខ្លួនជាអ្នកជិះបិទគូថ តែពុំបានសម្រេចត្រូវសមត្ថកិច្ចឃាត់ខ្លួនបាន។

- តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] សៀវម៉េង បានឆ្លើយថា៖ កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៦ និង៣០នាទី ជនរងគ្រោះឈ្មោះ [redacted] សៀវម៉េង បានជិះម៉ូតូមួយគ្រឿងម៉ាក HONDA C125 ស៊េរីឆ្នាំ២០០៩ ពណ៌ខ្មៅ ចេញពីកន្លែងធ្វើការនៅម្តុំផ្លូវលេខ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ ក្នុងគោលបំណងទៅជួបមិត្តភក្តិនៅម្តុំក្រោយមន្ទីរពេទ្យកុមារជាតិ ដោយជិះតាមបណ្តោយផ្លូវលេខ១២៨ លុះមកដល់ចំណុចមុខផាកកាហ្វេដែលមានទីតាំងផ្ទះលេខ៧០១ ផ្លូវលេខ១២៨ កែវផ្លូវលេខ២៥៧ ក្រុមទី១០ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពេលនោះខ្លួនបានឈប់ម៉ូតូម៉ូតូរួចបានលើកទូរស័ព្ទម៉ាក IPHONE XS ពណ៌ខ្មៅនិយាយទៅកាន់មិត្តភក្តិស្រាប់តែជនជាប់ចោទចំនួន០៣នាក់ មានឈ្មោះ ចំរើន ជិះម៉ូតូមួយគ្រឿងម៉ាកHONDA C125 ស៊េរីឆ្នាំ២០២០ ,ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ បុល ជិះម៉ូតូមួយគ្រឿងម៉ាក់ HONDA C125 ស៊េរីឆ្នាំ២០២១ ពណ៌ខ្មៅ ពុំចាំស្លាកលេខដោយជនជាប់ចោទឈ្មោះ សុខ វិចិត្រ ជិះម៉ូតូឌុបជនជាប់ចោទម្នាក់ទៀត(ជាអ្នកជិះបិទគូថ)ចំណែកជនជាប់ចោទម្នាក់ទៀតជិះម្នាក់ឯង ជាអ្នកធ្វើសកម្មភាពឆក់ បានជិះមកពីក្រោយខាងស្តាំដៃរបស់ខ្លួន រួចជនជាប់ចោទម្នាក់ទៀតដែលជិះម្នាក់ឯងក៏បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃខ្លួនបានសម្រេច រួចហើយជនជាប់ចោទទាំង០៣នាក់ បានជិះម៉ូតូបញ្ច្រាស់ផ្លូវគេចខ្លួន ភ្លាមនោះខ្លួនក៏បានស្រែកថាចោរៗ ដើម្បីឱ្យគេជួយក៏ត្រូវបានអ្នកដំណើរតាមផ្លូវបានជិះម៉ូតូដេញតាមជនជាប់ចោទឈ្មោះ [redacted] វិចិត្រ រហូតដល់ចំណុចមុខផ្ទះលេខ៤១២ ផ្លូវលេខ២៤៥ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ក៏បានដួលម៉ូតូភ្លាមនោះជនជាប់ចោទជាបក្សពួក០២នាក់ ក៏បានយកទូរស័ព្ទដៃរបស់ខ្លួនរួចជិះគេចខ្លួនបាត់ទៅ ចំណែកជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ក៏បានកម្លាំងសមត្ថកិច្ចបញ្ជូនមកកាន់ទីស្នាក់ការប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកល្អក់ទី១ ចាត់ការតាមនីតិវិធីច្បាប់តែម្តង។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ទ្រី បានឆ្លើយថា៖កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៦ និង៣០នាទី ខ្លួនកំពុងតែឈរលេងនៅមុខការ៉ាស់ឡាន(ឈ្មោះ រយខា) ស្ថិតនៅផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក៏លឺសំលេងក្មេងស្រីម្នាក់(ជនរងគ្រោះ) បានជិះម៉ូតូម៉ាក់HONDA C125 ពណ៌ខ្មៅ ជិះតាមផ្លូវរួចស្រែកថា ចោរៗ ឆក់ទូរស័ព្ទដៃជួយផងៗពេលនោះខ្លួនក៏បានឃើញមនុស្ស០៣នាក់ជិះម៉ូតូចំនួន០២គ្រឿង០១គ្រឿងជិះម្នាក់ឯងចំណែក០១គ្រឿងទៀតជិះមានគ្នា០២នាក់ ជាអ្នកជិះបិទគូទ ភ្លាមនោះខ្លួនក៏បានទាញម៉ូតូជិះដេញតាមពីក្រោយជនជាប់ចោទទាំង០៣នាក់រហូតមកដល់បេនឡានវិទ្ធិមុនី ផ្លូវលេខ២៤៥ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជនជាបចោទដែរជិះមានគ្នា០២នាក់ បានដួលម៉ូតូចំណែកជនជាប់ចោទជិះម្នាក់ឯងបានជិះគេចខ្លួនបាត់ ចំណែកជនជាប់ចោទដែលជិះបិទគូថ អ្នកជិះខាងក្រោយក៏បានលើម៉ូតូរបស់វារួចជិះគេចខ្លួនបាត់ដែរនៅសល់តែជនជាប់ចោទ០១នាក់ ក៏បានឃាត់ខ្លួនរួចចាំយកមកប្រគល់ឱ្យសមត្ថកិច្ចនគរបាលប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកល្អក់ទី១ ចាត់ការតាមផ្លូវច្បាប់តែម្តង។

## សេចក្តីសន្និដ្ឋានបួនសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោលរួចមកឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ដំបូងឡើយឆ្លើយដោះសារថាខ្លួនមិនបានចូលរួមក្នុងការឆក់ទូរស័ព្ទពីជនរងគ្រោះនោះទេ គឺខ្លួនគ្រាន់តែទៅរកកន្លែងផឹកស៊ីតែប៉ុណ្ណោះ ប៉ុន្តែក្រោយពីចៅក្រមជំនុំជម្រះអានកំណត់ហេតុចម្លើយនៅសមត្ថកិច្ច និងនៅចៅក្រមស៊ើបសួរឱ្យស្តាប់រួចមកជនជាប់ចោទបានឆ្លើយសារភាពនូវអំពើប្រព្រឹត្តដែលចម្លើយនេះស្របតាមរបាយការណ៍របស់សមត្ថកិច្ច ចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់សាក្សីមានភាពស៊ីសង្វាក់គ្នាអាច

បញ្ជាក់បានថាពិតជាមានអំពើ **លួចមានស្ថានទម្ងន់ទោស** ដូចការចោទប្រកាន់មែន ហេតុនេះតំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៣៦៧៨ អ.យ.ទ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ដដែល និងស្នើសុំទៅក្រុមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោលនៅអង្គសវនាការរួចមកឃើញថាកូនក្តីរបស់ខ្លួន មិនបានប្រព្រឹត្តលើដូចការចោទប្រកាន់នោះទេ កូនក្តីខ្លួនមិនបានចូលរួមក្នុងការឆក់ទូរស័ព្ទពីជនរងគ្រោះនោះឡើយ គឺខ្លួនគ្រាន់តែទៅរកកន្លែងផឹកស៊ីតែប៉ុណ្ណោះ បន្ទាប់មកខណៈដែលធ្វើដំណើរឈ្មោះ ចំរើន ក៏បានស៊ីផ្លេរហៅខ្លួនអោយបកក្រោយហើយក៏ឃើញឈ្មោះ ចំរើន បានធ្វើសកម្មភាពឆក់យកទូរស័ព្ទតែម្នាក់ឯង ពីស្ត្រីដែលនិយាយទូរស័ព្ទ។ដោយកូនក្តីខ្លួនឃើញបែបនេះក៏មានភាពស្ទន់ស្ទោរដោយសារតែឈ្មោះ ចំរើន ជាអ្នករួមដំណើរជាមួយគ្នានោះបានធ្វើសកម្មភាពឆក់យកទូរស័ព្ទដោយ កូនក្តីខ្លួនពុំបានដឹងអ្វីសោះ។ដូចនេះកូនក្តីខ្លួនមិនអាចឈប់នៅបកស្រាយតតាំងជាមួយជនរងគ្រោះ និងប្រជាពលរដ្ឋ ក្នុងខណៈពេលនោះបានទេ។កូនក្តីខ្លួនមានតែជិះម៉ូតូចាកចេញដោយជិះបែកផ្លូវពីឈ្មោះ ចំរើន ដោយសារភ័យក៏បានដួលម៉ូតូចំណែកឈ្មោះ បុល បានលើកម៉ូតូហើយជិះគេចខ្លួនបាត់ និងឈ្មោះ ចំរើន បានជិះយកទូរស័ព្ទទៅផ្លូវផ្សេងដោយគ្មានអ្នកដេញតាម។ សូមបញ្ជាក់បន្ថែមផងដែរថា កូមក្តីខ្លួនសូមប្បីតែទូរស័ព្ទម៉ាកអ្វីដែលឈ្មោះ ចំរើន បានឆក់ពីជនរងគ្រោះនោះ ក៏កូនក្តីខ្លួនមិនបានដឹងដែរមួយវិញទៀតកូនក្តីខ្លួនទើមតែពេញវ័យមានអាយុ១៨ឆ្នាំមិនចេះគិតគូរច្រើន។ដូចនេះចំពោះអំពើរបស់កូនក្តីខ្លួន គឺមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ក្នុងការ ចោទប្រកាន់កូនក្តីខ្លួនពីបទ **លួចមានស្ថានទម្ងន់ទោស** ទេដោយមូលហេតុថាកូនក្តីខ្លួនមិនបានធ្វើសកម្មភាពលួចដោយផ្ទាល់មិនបានធ្វើឱ្យជនរងគ្រោះមានរបួស មិនមានគម្រោងគិតទុកជាមុនក្នុងការលួច និងមិនមានគម្រោងយកទូរស័ព្ទនោះមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនផងដែរ ដែរជាហេតុគ្មានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** នោះឡើយ។ សំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់ចំពោះកូនក្តីខ្លួន **លួចមានស្ថានទម្ងន់ទោស** អោយមានសេរីភាពវិញ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **វិចិត្រ** បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសំណូមពរដល់តុលាការឱ្យខ្លួនរួចផុតបទចោទ។

## តុលាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ និងអំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិចារណាជាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ត្រូវបានចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថានពរលេខ ៣៦៧៨ អ.យ.ទ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាសម្រេចបញ្ជូនសំណុំ

រឿងមកជំនុំជម្រះលេខ ៤៩៦២ ង.ដ.ដ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ពីបទៈ **លួចមានស្ថានទម្ងន់ទោស** ដែលជាបទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.អង្គហេតុនៃចោទប្រកាន់បង្ហាញថាកាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៦ និង៣០ នាទី ជនរងគ្រោះឈ្មោះ [redacted] សៀវម៉េង បានជិះម៉ូតូមួយគ្រឿងម៉ាក HONDA C125 ស៊េរីឆ្នាំ២០០៩ ពណ៌ខ្មៅ ចេញពីកន្លែងធ្វើការនៅម្តុំផ្លូវលេខ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ ក្នុងគោលបំណងទៅជួបមិត្តភក្តិនៅម្តុំក្រោយមន្ទីរពេទ្យកុមារជាតិ ដោយជិះតាមបណ្តោយផ្លូវលេខ១២៨ លុះមកដល់ចំណុចមុខផាកការហ្វេដែលមានទីតាំងផ្ទះលេខ៧០១ ផ្លូវលេខ១២៨ កែងផ្លូវលេខ២៥៧ ក្រុមទី១០ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពេលនោះជនរងគ្រោះបានឈប់ម៉ូតូម៉ូតូរួចបានលើកទូរស័ព្ទម៉ាក IPHONE XS ពណ៌ខ្មៅ និយាយទៅកាន់មិត្តភក្តិ ស្រាប់តែជនជាប់ចោទចំនួន០៣នាក់ មានឈ្មោះ ចំរើន ជិះម៉ូតូមួយគ្រឿងម៉ាកHONDA C125 ស៊េរីឆ្នាំ២០២០ , ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ បុល ជិះម៉ូតូមួយគ្រឿងម៉ាក់ HONDA C125 ស៊េរីឆ្នាំ២០២១ ពណ៌ខ្មៅ ពុំចាំស្លាក់លេខដោយជនជាប់ចោទឈ្មោះ [redacted] វិចិត្រ និងឈ្មោះ បុល ជាអ្នជិះបិទគូថ ចំណែកជនជាប់ចោទឈ្មោះ ចំរើន ក៏បានធ្វើសកម្មភាពឆក់បានជិះម៉ូតូពីក្រោយខាងស្តាំដៃជនរងគ្រោះរួចជនជាប់ចោទឈ្មោះ ចំរើន បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃរបស់ជនរងគ្រោះបានសម្រេច រួចជនជាប់ចោទទាំង៣បានជិះម៉ូតូបញ្ច្រាស់ផ្លូវគេចខ្លួន ភ្លាមនោះជនរងគ្រោះក៏បានស្រែកថាចោរៗដើម្បីឲ្យគេជួយក៏ត្រូវបានអ្នកដំណើរតាមផ្លូវបានជិះម៉ូតូដេញតាមជនជាប់ចោទឈ្មោះ សុខ វិចិត្រ រហូតដល់ចំនុចផ្ទះលេខ៤១២ ផ្លូវលេខ២៤៥ ក្រុមទី៣១ ភូមិ១១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ក៏បានដួលម៉ូតូភ្លាមនោះ ជនជាប់ចោទឈ្មោះ បុល ដែលជិះខាងក្រោយក៏បានលើកម៉ូតូ ហើយជិះគេចខ្លួនបាត់ជាមួយឈ្មោះ ចំរើន បាត់តែម្តង។ប្រជាពលរដ្ឋចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted]ចិត្រ យកមកប្រគល់ជូនប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកល្អក់ទី១ ដើម្បីសាកសួរ។

៣.ជនជាប់ចោទឈ្មោះ [redacted]វិចិត្រ បានឆ្លើយថា៖ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១វេលាម៉ោង១៤ និង០០ នាទីរសៀល ឈ្មោះ បុល បានបបួលខ្លួនទៅផឹកស្រា ហើយខ្លួនក៏បានឲ្យឈ្មោះ បុល មកយកខ្លួននៅផ្ទះ។ពេលជិះតាមផ្លូវខ្លួនជាអ្នកឌុបឈ្មោះ បុល ហើយឈ្មោះ បុល ក៏បានទាក់ទងទៅឈ្មោះ ចំរើន មកជួបគ្នានៅស្តុបណ្ឌូគា។បន្ទាប់មកពួកខ្លួនក៏បានជិះម៉ូតូមកដល់ចំណុចសន្ធរមុខដើម្បីរកកន្លែងផឹកស៊ីក៏ស្រាប់តែឈ្មោះ ចំរើនបានស៊ីផ្លេឲ្យខ្លួនបកក្រោយវិញ ហើយឈ្មោះ ចំរើន បានជិះម៉ូតូទៅក្បែរជនរងគ្រោះដែលកំពុងឈរនិយាយទូរស័ព្ទ ហើយឈ្មោះ ចំរើន ក៏បានឆក់ទូរស័ព្ទពីជនរងគ្រោះបានសម្រេច។បន្ទាប់ជនរងគ្រោះក៏បានស្រែកថាចោរៗ។ពេលនោះពួកខ្លួនក៏បានជិះម៉ូតូគេចខ្លួនដោយឈ្មោះ ចំរើន ជិះបត់ទៅខាងឆ្វេងផ្លូវ ហើយជិះបត់ទៅខាងស្តាំផ្លូវ។បន្ទាប់ទៀតមានមនុស្សប្រុសពីរនាក់ជិះម៉ូតូម៉ាក PCX ដេញខ្លួនដល់ចំណុចបេនឡានវិទ្ធិមុនីផ្សារដើមគរ ហើយខ្លួនក៏ដួលម៉ូតូឈ្មោះ បុល ក៏បានលើកម៉ូតូជិះបាត់តែម្តង។ពេលគេក៏ហៅសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង។ខ្លួនមិនបានចូលរួមក្នុងការឆក់ទូរស័ព្ទពីជនរងគ្រោះនោះទេ គឺខ្លួនគ្រាន់តែទៅរកកន្លែងផឹកស៊ីតែប៉ុណ្ណោះ។ខ្លួនចេះប្រើប្រាស់គ្រឿងញៀនប្រហែលមួយអាទិត្យ មុនពេលកើតហេតុ។ចម្លើយដោះសាររបស់ជនជាប់ចោទថាខ្លួនមិនបានចូលរួមក្នុងសកម្មភាពឆក់ជាមួយឈ្មោះ ចំរើន និងឈ្មោះ បុល ពុំមានភស្តុតាងដែលអាចអោយតុលាការជឿបានឡើយ។ផ្ទុយទៅវិញជនជាប់ចោទបានឆ្លើយក្នុងកំណត់ហេតុហេតុសួរចម្លើយរបស់នគរបាលយុត្តិធម៌ថាមុនពេលចំរើនឆក់ទូរស័ព្ទជនរងគ្រោះបានស៊ីផ្លេរឲ្យខ្លួនជិះពីក្រោយមើលផ្លូវ។ពេលតុលាការសួរហើយអានចម្លើយឲ្យជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ស្តាប់ ជន

ជាប់ចោទបានឆ្លើយសារភាពថាខ្លួនបានចូលរួមក្នុងសកម្មភាពឆក់ទូរស័ព្ទដៃជនរងគ្រោះនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២១ ម៉ោង១៥ល្ងាចពិតប្រាកដមែន។

៤.អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] សៀវម៉េង បានឆ្លើយថា៖ កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៦ និង៣០នាទី ជនរងគ្រោះឈ្មោះ [redacted] សៀវម៉េង បានជិះម៉ូតូមួយគ្រឿងម៉ាក HONDA C125 ស៊េរីឆ្នាំ២០០៩ ពណ៌ខ្មៅ ចេញពីកន្លែងធ្វើការនៅម្តុំផ្លូវលេខ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ ក្នុងគោលបំណងទៅជួបមិត្តភក្តិនៅម្តុំក្រោយមន្ទីរពេទ្យកុមារជាតិ ដោយជិះតាមបណ្តោយផ្លូវលេខ១២៨ លុះមកដល់ចំណុចមុខដាកការហ្វេដែលមានទីតាំងផ្ទះលេខ៧០១ ផ្លូវលេខ១២៨ កែងផ្លូវលេខ២៥៧ ក្រុមទី១០ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពេលនោះខ្លួនបានឈប់ម៉ូតូរួចបានលើកទូរស័ព្ទម៉ាក IPHONE XS ពណ៌ខ្មៅ និយាយទៅកាន់មិត្តភក្តិស្រាប់តែជនជាប់ចោទចំនួន០៣នាក់ មានឈ្មោះ ចំរើន ជិះម៉ូតូមួយគ្រឿងម៉ាកHONDA C125 ស៊េរីឆ្នាំ២០២០ ,ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ បុល ជិះម៉ូតូមួយគ្រឿងម៉ាក់ HONDA C125 ស៊េរីឆ្នាំ ២០២១ ពណ៌ខ្មៅ ពុំចាំស្លាក់លេខដោយជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ជិះម៉ូតូឌុបជនជាប់ចោទម្នាក់ទៀត(ជាអ្នកជិះបិតគូថ)ចំណែកជនជាប់ចោទម្នាក់ទៀតជិះម្នាក់ឯង ជាអ្នកធ្វើសកម្មភាពឆក់ បានជិះមកពីក្រោយខាងស្តាំដៃរបស់ខ្លួន រួចជនជាប់ចោទម្នាក់ទៀតដែលជិះម្នាក់ឯងក៏បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃខ្លួនបានសម្រេច រួចហើយជនជាប់ចោទទាំង០៣នាក់ បានជិះម៉ូតូបញ្ច្រាស់ផ្លូវគេចខ្លួន ភ្លាមនោះខ្លួនក៏បានស្រែថាចោរៗ ដើម្បីឲ្យគេជួយក៏ត្រូវបានអ្នកដំណើរតាមផ្លូវបានជិះម៉ូតូដេញតាមជនជាប់ចោទឈ្មោះ [redacted] វិចិត្រ រហូតដល់ចំណុចមុខផ្ទះលេខ៤១២ ផ្លូវលេខ២៤៥ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ក៏បានដួលម៉ូតូភ្លាមនោះជនជាប់ចោទជាបក្សពួក០២នាក់ ក៏បានយកទូរស័ព្ទដៃរបស់ខ្លួនរួចជិះគេចខ្លួនបាត់ទៅ ចំណែកជនជាប់ចោទឈ្មោះ សុខ វិចិត្រ ក៏បានកម្លាំងសមត្ថកិច្ចបញ្ជូនមកកាន់ទីស្នាក់ការប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកល្អក់ទី១ ចាត់ការតាមនីតិវិធីច្បាប់តែម្តង។ ចម្លើយជនរងគ្រោះស៊ីសង្វាក់ទៅនឹងចម្លើយសារភាពរបស់ជនជាប់ចោទ អាចអោយតុលាការជឿបាន។

៥.អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ទ្រី បានឆ្លើយថា៖កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៦ និង៣០នាទី ខ្លួនកំពុងតែឈរលេងនៅមុខកាវ៉ាស់ឡាន(ឈ្មោះ រយខា) ស្ថិតនៅផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក៏លឺសំលេងក្មេងស្រីម្នាក់(ជនរងគ្រោះ) បានជិះម៉ូតូម៉ាក់HONDA C125 ពណ៌ខ្មៅ ជិះតាមផ្លូវរួចស្រែកថា ចោរៗ ឆក់ទូរស័ព្ទដៃជួយផងៗពេលនោះខ្លួនក៏បានឃើញមនុស្ស០៣នាក់ជិះម៉ូតូចំនួន០២គ្រឿង ០១គ្រឿងជិះម្នាក់ឯងចំណែក០១គ្រឿងទៀតជិះមានគ្នា០២នាក់ ជាអ្នកជិះបិទគូទ ភ្លាមនោះខ្លួនក៏បានទាញម៉ូតូជិះដេញតាមពីក្រោយជនជាប់ចោទទាំង០៣នាក់រហូតមកដល់បេនឡានរិទ្ធិមុនី ផ្លូវលេខ២៤៥ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជនជាបចោទដែរជិះមានគ្នា០២នាក់ បានដួលម៉ូតូចំណែកជនជាប់ចោទជិះម្នាក់ឯងបានជិះគេចខ្លួនបាត់ ចំណែកជនជាប់ចោទដែលជិះបិទគូទ អ្នកជិះខាងក្រោយក៏បានលើម៉ូតូរបស់វារួចជិះគេចខ្លួនបាត់ដែរនៅសល់តែជនជាប់ចោទ០១នាក់ ក៏បានឃាត់ខ្លួនរួចចាំយកមកប្រគល់ឲ្យសមត្ថកិច្ចនគរបាលប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកល្អក់ទី១ ចាត់ការតាមផ្លូវច្បាប់តែម្តង។ចម្លើយរបស់សាក្សីច្បាស់លាស់ស៊ីសង្វាក់ទៅនឹងចម្លើយជនជាប់ចោទ និងចម្លើយជនរងគ្រោះដែលអាចឲ្យតុលាការជឿបាន។

៦.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោលរួចមកឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ដំបូងឡើយឆ្លើយដោះសារថាខ្លួនមិនបានចូលរួមក្នុងការឆក់ទូរស័ព្ទពីជនរងគ្រោះនោះទេ គឺខ្លួនគ្រាន់តែទៅរកកន្លែងផឹកស៊ីតែប៉ុណ្ណោះ ប៉ុន្តែក្រោយពីចៅក្រមជំនុំជម្រះអានកំណត់ហេតុចម្លើយនៅ



Scanned with CamScanner

សមត្ថកិច្ច និងនៅចៅក្រមស៊ើបសួរឱ្យស្ដាប់រួចមកជនជាប់ចោទបានឆ្លើយសារភាពនូវអំពើប្រព្រឹត្តដែលចម្លើយនេះស្របតាមរបាយការណ៍របស់សមត្ថកិច្ច ចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់សាក្សីមានភាពស៊ីសង្វាក់គ្នាអាចបញ្ជាក់បានថាពិតជាមានអំពើ **លួចមានស្ថានទម្ងន់ទោស** ដូចការចោទប្រកាន់មែន ហេតុនេះតំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៣៦៧៨ អ.យ.ទ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ដដែល និងស្នើសុំចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ ការសន្និដ្ឋានប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណា។

៧.លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោលនៅអង្គសវនាការរួចមកឃើញថាកូនក្តីរបស់ខ្លួន មិនបានប្រព្រឹត្តលើដូចការចោទប្រកាន់នោះទេ កូនក្តីខ្លួនមិនបានចូលរួមក្នុងការឆក់ទូរស័ព្ទពីជនរងគ្រោះនោះឡើយ គឺខ្លួនគ្រាន់តែទៅរកកន្លែងផឹកស៊ីតែប៉ុណ្ណោះ បន្ទាប់មកខណៈដែលធ្វើដំណើរឈ្មោះ ចំរើន ក៏បានស៊ីផ្លេរហៅខ្លួនអោយបកក្រោយហើយក៏ឃើញឈ្មោះ ចំរើន បានធ្វើសកម្មភាពឆក់យកទូរស័ព្ទតែម្នាក់ឯង ពីស្ត្រីដែលនិយាយទូរស័ព្ទ។ដោយកូនក្តីខ្លួនឃើញបែបនេះក៏មានភាពស្ទន់ស្ទេរដោយសារតែឈ្មោះ ចំរើន ជាអ្នករួមដំណើរជាមួយគ្នានោះបានធ្វើសកម្មភាពឆក់យកទូរស័ព្ទដោយ កូនក្តីខ្លួនពុំបានដឹងអ្វីសោះ។ដូចនេះកូនក្តីខ្លួនមិនអាចឈប់នៅបកស្រាយតតាំងជាមួយជនរងគ្រោះ និងប្រជាពលរដ្ឋ ក្នុងខណៈពេលនោះបានទេ។កូនក្តីខ្លួនមានតែជិះម៉ូតូចាកចេញដោយជិះបែកផ្លូវពីឈ្មោះ ចំរើន ដោយសារភ័យក៏បានដួលម៉ូតូ ចំណែកឈ្មោះ បុល បានលើកម៉ូតូហើយជិះគេចខ្លួនបាត់ និងឈ្មោះ ចំរើន បានជិះយកទូរស័ព្ទទៅផ្លូវផ្សេងដោយគ្មានអ្នកដេញតាម។ សូមបញ្ជាក់បន្ថែមផងដែរថា កូមក្តីខ្លួនសូមប្បីតែទូរស័ព្ទម៉ាកអ្វីដែលឈ្មោះ ចំរើន បានឆក់ពីជនរងគ្រោះនោះ ក៏កូនក្តីខ្លួនមិនបានដឹងដែរមួយវិញទៀតកូនក្តីខ្លួនទើបតែពេញវ័យមានអាយុ១៩ឆ្នាំមិនចេះគិតគូរច្រើន។ដូចនេះចំពោះអំពើរបស់កូនក្តីខ្លួន គឺមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ក្នុងការ ចោទប្រកាន់កូនក្តីខ្លួនពីបទ **លួចមានស្ថានទម្ងន់ទោស** ទេដោយមូលហេតុថាកូនក្តីខ្លួនមិនបានធ្វើសកម្មភាពលួចដោយផ្ទាល់មិនបានធ្វើឲ្យជនរងគ្រោះមានរបួស មិនមានគម្រោងគិតទុកជាមុនក្នុងការលួច និងមិនមានគម្រោងយកទូរស័ព្ទនោះមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនផងដែរ ដែរជាហេតុគ្មានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** នោះឡើយ។ សំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់ចំពោះកូនក្តីខ្លួន **លួចមានស្ថានទម្ងន់ទោស** អោយមានសេរីភាពវិញ ។សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ ដែលថាជនជាប់ចោទមិនបានប្រព្រឹត្តគឺពុំត្រឹមត្រូវនោះទេ ហើយផ្ទុយទៅនឹងចម្លើយសារភាពរបស់ជនជាប់ចោទនាពេលសវនាការ បានឆ្លើយសារភាពថាខ្លួនពិតជាបានចូលរួមក្នុងអំពើឆក់ក្នុងអង្គហេតុនេះពិតប្រាកដ។សេចក្តីសន្និដ្ឋានការពាររបស់មេធាវី តុលាការមិនយកមកពិចារណាឡើយ។

៨.អំពើរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនិងរបៀបរៀបរយសង្គមដែលច្បាប់បានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសតាមច្បាប់។

៩.ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ជានីតិជន ហើយពុំមានភស្តុតាងបញ្ជាក់ថាមានបញ្ហាខាងស្មារតីឡើយ ។ជនជាប់ចោទមានស្មារតីល្អ អាចយល់ដឹងបានពីហេតុនិងបច្ច័យដែលកើតចេញពីអំពើរបស់ខ្លួន។ជនជាប់ចោទត្រូវទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

១០.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **វិចិត្រ** ភេទប្រុស កើតឆ្នាំ២០០៣ ជនជាតិខ្មែរ (អត្តសញ្ញាណដូចខាងលើ) ពីបទ៖ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៧០៦ ផ្លូវលេខ



Scanned with CamScanner

១២៨ កែងផ្លូវលេខ២៥៧ ក្រុមទី៣៥ ភូមិ១០ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,៣៥៧ នៃ ក្រមព្រហ្មទណ្ឌ។

១១.សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ឲ្យតុលាការជួយបន្ធូរបន្ថយទោសឲ្យខ្លួនផងតុលាការយកមកពិចារណាផ្តន្ទាទោសជនជាប់ចោទត្រឹមអប្បបរមានៃទោសដែលច្បាប់កំណត់ពីព្រោះជនជាប់ចោទមិនទាន់ត្រូវបានតុលាការផ្តន្ទាទោសជាស្ថាពរអោយជាប់ពន្ធនាគារក្នុងរយៈពេល៥ឆ្នាំមុនអំពើល្មើសនេះទេ។ជនជាប់ចោទនៅវ័យក្មេងអាចកែប្រែទៅជាពលរដ្ឋល្អក្នុងសង្គមវិញបាន។អំពើរបស់ជនជាប់ចោទពុំទាន់មានព្យសនកម្មដល់ជនរងគ្រោះ ឬធ្វើអោយជនរងគ្រោះមានគ្រោះថ្នាក់នោះទេ។

១២.ជនរងគ្រោះឈ្មោះ [redacted] សៀវម៉េង បានដាក់ពាក្យបណ្តឹងនៅតំណាក់កាលសមត្ថកិច្ចនគរបាល ជាលក្ខណៈបណ្តឹងបរិហា ដោយជនជាប់ចោទមិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងជម្ងឺចិត្តពីជនជាប់ចោទនោះឡើយ តុលាការមិនពិចារណា និងសម្រេចអំពីសំណងរដ្ឋប្បវេណីនោះទេ។

## ហេតុដូច្នេះសម្រេច

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **វិចិត្រ** ហៅ **សាល** ភេទប្រុស កើតឆ្នាំ២០០៣ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ០៣(បី) ឆ្នាំ ។

ពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៧០១ ផ្លូវលេខ១២៨ កែងផ្លូវលេខ២៥៧ ក្រុមទី៣៥ ភូមិ១០ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វិចិត្រ។

ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និង ត្រា ៖ | ហត្ថលេខា និង ត្រា ៖ | ហត្ថលេខា និង ត្រា ៖ | ហត្ថលេខា និង ត្រា ៖ |

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៨រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner